# ដាក់មានះចៀសភ្តីទុក្ខ

**បទពាក្យ៩**

ព្រះពុទ្ធអង្គ ទ្រង់ប្រកាស ត្រាស់ពាក្យពិត
សែនស័ក្តិសិទ្ធិ ឥតមានល្បើង ទៀងបានផល
ប្រាប់បរិស័ទ កាត់មានះ លះអំពល់
នឹងបានយល់ ឋានផុតខ្វល់ ដល់សុខា ។
ធម៌មានះ ព្រះត្រាស់ថា ការរឹងរូស
ប្រកាន់ខុស លុះអំណាច អង្គអាត្មា
តំកើងខ្លួន ស្ងួនខាងយស ហួសធម្មតា
ដោយគិតថា គ្មាននរណា នឹងស្មើខ្លួន ។
មិនព្រមស្តាប់ ត្រាប់មិនបាន ពាក្យប្រដៅ
ចិត្តមិននៅ ទៅមិនដល់ ទីសមសួន
អាងលើទ្រព្យ ជាប់ចំណេះ ថាមាំមួន
ប្រកាន់ខ្លួន មិនខ្ចីស្ងួន ពឹងនរណា ។
មានះបាំង តាំងអោយខ្វាត់ បាត់អស់មិត្ត
ទោះឆ្ងាយជិត ពិតចេញឆ្ងាយ ណាយអសារ
មានះបាំង ញុំាងកុសល ផលផ្លែផ្កា
អោយបរា ត្រាធ្លាក់ទៅ ផ្លូវអភ័ព្វ ។
ដាក់មានះ ចៀសប្រជែង លែងកំព្រា
សុខរមនា ជាភិយ្យោ ហូរចូលជាប់
មិត្តភ័ក្តិផង ចងសំលាញ់ កាញ់គំនាប់
សិរីភ័ព្វ ជាប់កិត្តិយស រស់សុខសាន្ត ។

Ca. ០៧ ឧសភា ២០០៦

ភិក្ខុ ស្វាត សាលឿម